ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

លេខ ៦៩.១.០.៣......សផស

# សេចក្តីណែនាំ
# ស្តីពី
# ការហាមឃាត់ប្រើប្រាស់សារធាតុហាមឃាត់ អង់ទីប៊ីយូទិកហាមឃាត់ សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់ខុសប្រក្រតី ផលិតផលសារពាង្គកាយរស់កែច្នៃសេនេទិកហាមឃាត់សម្រាប់ចំណីសត្វ

កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញនូវប្រកាសមួយចំនួនស្ថិតក្រោមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដែលប្រកាសទាំងនេះទាក់ទងការគ្រប់គ្រងការចិញ្ចឹមសត្វនៅតាមទីកន្លែងឬកសិដ្ឋានចិញ្ចឹមសត្វ ការគ្រប់គ្រង ការធ្វើពាណិជ្ជកម្ម ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំ លក់រាយ និងការដឹកជញ្ជូនចំណីសត្វ សារធាតុបន្ថែមផ្សំចំណីសត្វ និងបសុឱសថ ក្នុងគោលបំណងជំរុញផលិតកម្មនិងផលិតភាពសត្វ បង្ការទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ និងជំងឺស៊ូណូស ការពារសុខភាពសត្វ សុខុមាលភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន ព្រមទាំងធានានូវផលិតផលសត្វមានអនាម័យ មានគុណភាព និងសុវត្ថិភាពសម្រាប់អ្នកបរិភោគ។

ទោះបីជាមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងមានយុទ្ធនាការផ្សព្វផ្សាយយ៉ាងទូលំទូលាយជូនដល់បណ្តាអ្នកពាក់ព័ន្ធ ជាពិសេសកសិដ្ឋានចិញ្ចឹមសត្វ រោងចក្រនិងទីកន្លែងផលិតចំណីសត្វ ក្រុមហ៊ុនធ្វើពាណិជ្ជកម្ម និងដេប៉ូលក់ចំណីសត្វ សារធាតុបន្ថែមផ្សំចំណីសត្វ និងបសុឱសថ ក៏ដូចជាការផ្សព្វផ្សាយ និងណែនាំដល់អ្នកចិញ្ចឹមសត្វ និងសមាគមអ្នកចិញ្ចឹមសត្វ ឬតាមរយៈការចុះធ្វើអធិការកិច្ចនៅតាមបណ្តារាជធានី-ខេត្ត អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសង្កេតឃើញថា ការធ្វើពាណិជ្ជកម្ម ការផលិតលាយផ្សំ ការលក់ដូរ និងការប្រើប្រាស់ចំណីសត្វ សារធាតុបន្ថែមផ្សំចំណីសត្វ និងបសុឱសថនៅមានភាពខ្វះចន្លោះប្រហោង បំពានលើច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំរបស់សមត្ថកិច្ចជំនាញនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ជាពិសេសការប្រើប្រាស់ ការផលិតលាយផ្សំ និងការធ្វើពាណិជ្ជកម្មចំណីសត្វ ឬបសុឱសថ ដែលមានសារធាតុហាមឃាត់ សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់របស់សត្វខុសប្រក្រតី ការប្រើប្រាស់អង់ទីប៊ីយូទិកហាមឃាត់លើសការកំណត់ ឬប្រើផលិតផលសារពាង្គកាយរស់កែច្នៃសេនេទិកហាមឃាត់ ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតសត្វ និងមនុស្ស។

ដើម្បីទប់ស្កាត់ និងបញ្ចៀសឱ្យបាននូវហានីភ័យដែលអាចកើតមានឡើងដោយសារការបំពានខាងលើនេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សូមធ្វើការណែនាំដល់កសិដ្ឋានចិញ្ចឹមសត្វ អ្នកចិញ្ចឹមសត្វ រោងចក្រ និងទីកន្លែងផលិតចំណីសត្វ ក្រុមហ៊ុនធ្វើពាណិជ្ជកម្ម និងដេប៉ូលក់ចំណីសត្វ សារធាតុបន្ថែមផ្សំចំណីសត្វនិងបសុឱសថ សមាគមអ្នកចិញ្ចឹមសត្វនូវវិធានការដូចខាងក្រោម៖

ភូមិទ្រា ផ្លូវលេខ ៣៧១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កម្ពុជា
Trea Village, Str. 371, Sangkat Steung Mean Chey, Khan Mean Chey, Phnom Penh Cambodia
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៨៣ ៧៤៦/៨៨៤ ១៤៨ ទូរសារ: (៨៥៥) ២៣ ៨៨៣ ៧៤៦/៨៨៤ ១៤៨
Tel.: (855) 23 883 746/884 148 Fax.: (855) 23 883 746/884 148

១. ហាមឃាត់ប្រើប្រាស់អង់ទីប៊ីយូទិកដូចជា Chloramphenicol, Clenbuterol, Fluoroquinolones, Glycopeptides, Vancomycin, Nitromidazoles, Dimetridazole, Ipronidazole, Meteronidazole និងថ្នាក់របស់វា Sulfonamide និងអង់ទីប៊ីយូទិកហាមឃាត់ដទៃទៀតដែលមានចែងក្នុង Codex Alimentarius សម្រាប់ចំណីសត្វ។

២. ហាមឃាត់ប្រើប្រាស់សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់របស់សត្វខុសប្រក្រតី ផលិតផលសារពាង្គកាយរស់កែច្នៃសេនេទិកហាមឃាត់ ឬឱសថហាមឃាត់សម្រាប់ចំណីសត្វ ដែលបង្កគ្រោះថ្នាក់ដល់សុខភាព ជីវិតសត្វ និងមនុស្ស។

៣. កសិដ្ឋានចិញ្ចឹមសត្វត្រូវប្រើប្រាស់សារធាតុគីមី និងថ្នាំសម្លាប់មេរោគដែលត្រូវបានអនុញ្ញាតដោយច្បាប់ និងតាមបទដ្ឋានរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ។

៤. កសិដ្ឋានចិញ្ចឹមសត្វត្រូវធ្វើការកត់ត្រាការប្រើប្រាស់ចំណី ទឹក និងបសុឱសថ និងថ្ងៃដែលសត្វចាប់ផ្ដើមចិញ្ចឹម-លក់ ដោយមានសៀវភៅកត់ត្រាការប្រើប្រាស់សម្រាប់ការធ្វើអធិការកិច្ច។

៥. ចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមផ្សំចំណីសត្វ និងបសុឱសថ ត្រូវធ្វើការចុះបញ្ជីមុនធ្វើពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦. រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតធ្វើអាជីវកម្ម ពាណិជ្ជកម្ម ឬធ្វើសេវាកម្មគ្រប់រូបភាពពាក់ព័ន្ធនឹងចំណីសត្វ និងបសុឱសថត្រូវធ្វើការកត់ត្រាព័ត៌មានស្ដីពីការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិតលាយផ្សំ ការវេចខ្ចប់សារជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំ លក់រាយនូវចំណីសត្វ សារធាតុបន្ថែមផ្សំចំណីសត្វ និងបសុឱសថ ដោយត្រូវប្រើនូវសៀវភៅកំណត់ត្រាចែងក្នុងគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា ក្រោយទទួលបាននូវសេចក្ដីណែនាំខាងលើ អ្នកចិញ្ចឹមសត្វ ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វ ក្រុមហ៊ុនផលិតចំណីសត្វ ផលិតករ ពាណិជ្ជករ ប្រតិបត្តិករ សមាគមអ្នកចិញ្ចឹមសត្វ ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមអនុវត្តនូវបណ្ដាវិធានការដូចមានចែងក្នុងសេចក្ដីណែនាំនេះ។ ករណីបំពានលើការហាមឃាត់ដូចមានចែងក្នុងសេចក្ដីណែនាំនេះ នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

**តាន់ ផាន់ណារ៉ា**

**ចម្លងជូន៖**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្តន៍"
- ឯកសារ កាលប្បវត្តិ